AEC
Australian Electoral Commission

*Your vote is a valuable thing*



# ការណែនាំដើម្បីចុះឈ្មោះ ហើយបោះឆ្នោតនៅក្នុងការបោះឆ្នោតសហព័ន្ធ

## ហេតុអ្វីបានជាខ្ញុំត្រូវចុះឈ្មោះ មុននឹងខ្ញុំអាចបោះឆ្នោត?

សិទ្ធិដើម្បីបោះឆ្នោតគឺជាឯកសិទ្ធិមួយក្នុងចំណោមឯកសិទ្ធិទាំងឡាយទៀតនៃការរស់នៅក្នុងប្រទេសលិទ្ធិប្រជាធិបតេយ្យ – លោកអ្នកមានសិទ្ធិជ្រើសរើសនរណាឲ្យមើលគ្រប់គ្រងប្រទេសរបស់លោកអ្នក។

នៅក្នុងប្រទេសអូស្ត្រាលី ការចុះឈ្មោះ និងការបោះឆ្នោតគឺជាការចាំបាច់ដែលត្រូវធ្វើដោយខានពុំបានទៅតាមច្បាប់។ សំខាន់ជាងគេ នេះគឺជាឱកាសរបស់លោកអ្នកដើម្បីជ្រើសរើសអ្នកតំណាងលោកអ្នកនៅក្នុងសភាសហព័ន្ធ។

ពេលណាលោកអ្នកចុះឈ្មោះបោះឆ្នោត ឈ្មោះ ហើយនិងអាសយដ្ឋានរបស់លោកអ្នកត្រូវគេដាក់ចូលក្នុងបញ្ជីបោះឆ្នោតសហព័ន្ធ ជាបញ្ជីនៃអ្នកបោះឆ្នោតដែលមានសិទ្ធិបោះឆ្នោត។

លោកអ្នកត្រូវចុះឈ្មោះ ហើយបោះឆ្នោត ប្រសិនបើលោកអ្នកជាពលរដ្ឋអូស្ត្រាលី ហើយមានអាយុ១៨ឆ្នាំ ហើយច្រើនជាងនេះ។

លោកអ្នកអាចចុះឈ្មោះ ប្រសិនបើលោកអ្នកមានអាយុ១៧ឆ្នាំ។ តាមវិធីនេះ លោកអ្នកនឹងមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ហើយអាចបោះឆ្នោតពេលណាលោកអ្នកចូលអាយុ១៨ឆ្នាំ។

បញ្ជីបោះឆ្នោតនឹងត្រូវបិទក្នុងពេលយ៉ាងខ្លី បន្ទាប់ពីរដ្ឋាភិបាលបានប្រកាសអំពីថ្ងៃបោះឆ្នោត ហើយប្រសិនបើលោកអ្នកពុំមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតទេ លោកអ្នកមិនអាចបោះឆ្នោតបានឡើយ។ មានពេលកំណត់ខុសៗគ្នាសំរាប់ការបោះឆ្នោតសហព័ន្ធ រដ្ឋ / ដែនដី ហើយនិងសាលាសង្កាត់។ ហេតុដូច្នេះលោកអ្នកគួរចុះឈ្មោះ ហើយរក្សាការចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតដើម្បីឲ្យបានច្បាស់ប្រាកដថាលោកអ្នកមិនខកក្នុងការបោះឆ្នោត។

## តើខ្ញុំចុះឈ្មោះដោយបែបណា?

សូមគ្រាន់តែបំពេញពាក្យចុះឈ្មោះបោះឆ្នោះ ផ្តល់ភស្តុតាងនៃអត្តសញ្ញាណ (លេខប័ណ្ណបើកបររថយន្ត ប្រសិនបើលោកអ្នកមាន) ហើយលោកអ្នកនឹងត្រូវគេដាក់ចូលទៅក្នុងបញ្ជីបោះឆ្នោត។ ប្រសិនបើលោកអ្នកពុំមានប័ណ្ណបើកបររថយន្តទេ សូមអានពាក្យចុះឈ្មោះបោះឆ្នោះ ដើម្បីប្រើជំរើសផ្សេងទៀត។

ពាក្យបំពេញតែមួយនឹងចុះឈ្មោះលោកអ្នកសំរាប់ការបោះឆ្នោតសហព័ន្ធ រដ្ឋ / ដែនដី ហើយនិងសាលាសង្កាត់។

នៅក្នុងរយៈពេលពីរ ឬបីសប្តាហ៍ លោកអ្នកនឹងបានទទួលលិខិតមួយច្បាប់ដែលបញ្ជាក់ប្រាប់លោកអ្នកអំពីការចុះឈ្មោះបោះឆ្នោតរបស់លោកអ្នក។

## តើខ្ញុំអាចទទួលពាក្យចុះឈ្មោះបោះឆ្នោះពីកន្លែងណា?

- ទាញយកពាក្យបំពេញពីវ៉ិបសាយ – www.aec.gov.au
- ហាងប្រៃសណីយ៍ Australia Post
- ការិយាល័យ Australian Electoral Commission (AEC) (គណៈកម្មការចាត់ចែងការបោះឆ្នោតអូស្ត្រាលី) ណាមួយ
- វ៉ិបសាយរបស់ក្រសួងពន្ធដារ
- មជ្ឈមណ្ឌលអតិថិជន Centrelink
- ការិយាល័យ Medicare (មេឌីឃែរ)
- មណ្ឌលកិច្ចការជំនួយនៅតាមទីជនបទខ្លះ

## តើខ្ញុំអាចរក្សាការចុះឈ្មោះឲ្យបានត្រឹមត្រូវដោយបែបណា?

គ្រប់ពេលណាដែលលោកអ្នកផ្លាស់ប្តូរអាសយដ្ឋានរបស់លោកអ្នក – រើទៅម្ខាងផ្លូវទៀត ឬរើទៅកាន់រដ្ឋផ្សេងទៀត – ឬផ្លាស់ប្តូរឈ្មោះរបស់លោកអ្នក លោកអ្នកនឹងត្រូវការបំពេញពាក្យថ្មីមួយ។ ការនេះនឹងចុះឈ្មោះលោកអ្នកនៅកន្លែងថ្មីរបស់លោកអ្នក ឬរក្សាឈ្មោះថ្មីរបស់លោកអ្នកឲ្យបានទាន់ពេល ហើយយកចេញឈ្មោះចាស់របស់លោកអ្នកក្នុងជំហានងាយស្រួលមួយ។

ប្រសិនបើលោកអ្នកមិនរក្សាព័ត៌មានលំអិតរបស់លោកអ្នក ឲ្យបានទាន់ពេលទេ ឈ្មោះរបស់លោកអ្នកអាចត្រូវគេយកចេញពីបញ្ជីបោះឆ្នោត ដែលមានន័យថាលោកអ្នកអាចបាត់បង់ឱកាសរបស់លោកអ្នកដើម្បីបោះឆ្នោត។

ប្រសិនបើលោកអ្នកមិនអាចរកឃើញលិខិតរបស់លោកអ្នកដែលគេផ្ញើមកពី AEC ដែលបញ្ជាក់នូវព័ត៌មានលំអិតនៃការចុះឈ្មោះរបស់លោកអ្នក លោកអ្នកអាចឆែកមើលនៅត្រង់វ៉ិបសាយរបស់ AEC ឬទូរស័ព្ទលេខ **13 23 26**។

## តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើខ្ញុំធ្វើដំណើរទៅបរទេស?

នេះមិនមែនជាការដែលត្រូវធ្វើដោយខានពុំបានដើម្បីចុះឈ្មោះ ឬបោះឆ្នោតឡើយប្រសិនបើលោកអ្នកនៅក្រៅប្រទេសអូស្ត្រាលី។ ប្រសិនបើលោកអ្នកធ្វើដំណើរទៅបរទេសសំរាប់ការកំសាន្ត ឬសំរាប់រយៈពេលវែង លោកអ្នកគួរប្រាប់ AEC ឲ្យបានដឹង។ ប្រសិនបើលោកអ្នកមិនបានប្រាប់ទេ លោកអ្នកនឹងប្រថុយដោយត្រូវគេលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត។

KHMER








## ចុះប្រសិនបើខ្ញុំត្រូវការរក្សាអាសយដ្ឋានរបស់ខ្ញុំជាឯកជន?

លោកអ្នកអាចដាក់ពាក្យសុំចុះឈ្មោះថាជាអ្នកបោះឆ្នោតសម្ងាត់ ប្រសិនបើលោកអ្នកមានការភ័យខ្លាចថា ការបោះពុម្ពផ្សាយអាសយដ្ឋានរបស់លោកអ្នកនៅក្នុងបញ្ជីបោះឆ្នោតអាចដាក់សុវត្ថិភាពរបស់លោកអ្នក ឬគ្រួសាររបស់លោកអ្នកស្ថិតនៅក្នុងសភាពគ្រោះថ្នាក់។

លោកអ្នកអាចទទួលយកពាក្យបំពេញ និងព័ត៌មានបន្ថែមទៀតបានពីវិបសាយរបស់ AEC ឬដោយទូរស័ព្ទលេខ **13 23 26**។

## តើខ្ញុំត្រូវបោះឆ្នោតនៅពេលណា ហើយនៅទីណា?

ថ្ងៃបោះឆ្នោតសហព័ន្ធតែងធ្វើឡើងនៅថ្ងៃសៅរ៍។ ការបោះឆ្នោតធ្វើឡើងរវាងម៉ោង៨ព្រឹក និងម៉ោង៦យប់នៅតាមកន្លែងបោះឆ្នោតពេញទូទាំងប្រទេស។ កន្លែងដែលលោកអ្នកនឹងត្រូវបោះឆ្នោតនៅថ្ងៃបោះឆ្នោត គឺសំរេចទៅលើរបៀបយ៉ាងណាដែលលោកអ្នកអាចបោះឆ្នោត។

ប្រសិនបើលោកអ្នកនៅក្នុងតំបន់របស់លោកអ្នក លោកអ្នកអាចបោះឆ្នោតនៅតាមកន្លែងបោះឆ្នោតណាមួយក៏បាន នៅក្នុងមណ្ឌលបោះឆ្នោតរបស់លោកអ្នក។ កន្លែងបោះឆ្នោតនឹងមានចុះផ្សាយនៅតាមវិបសាយរបស់ AEC និងនៅតាមសារព័ត៌មានធំៗនៅថ្ងៃសុក្រមុនថ្ងៃបោះឆ្នោត។

ប្រសិនបើលោកអ្នកនៅក្នុងរដ្ឋ ឬដែនដីរបស់លោកអ្នក ក៏ប៉ុន្តែនៅក្រៅមណ្ឌលបោះឆ្នោតរបស់លោកអ្នក លោកអ្នកអាចបោះឆ្នោតនៅតាមកន្លែងបោះឆ្នោតណាមួយក៏បាន។ ការបោះឆ្នោតនេះហៅថា ការបោះឆ្នោតអវត្តមាន។

ប្រសិនបើលោកអ្នកនឹងនៅក្នុងរដ្ឋ ឬដែនដីផ្សេងទៀត លោកអ្នកអាចបោះឆ្នោតបានតែនៅតាមមណ្ឌលបោះឆ្នោតពិសេសក្នុងរដ្ឋប៉ុណ្ណោះ។ ទីកន្លែងបោះឆ្នោតនឹងមានចុះផ្សាយនៅចំពេលបោះឆ្នោត។ ផ្សេងពីនេះវិញនោះ លោកអ្នកអាចបោះឆ្នោតមុននឹងលោកអ្នកចាកចេញពីផ្ទះ ឬលោកអ្នកអាចដាក់ពាក្យសុំដើម្បីឲ្យគេផ្ញើសន្លឹកឆ្នោតទៅជូនលោកអ្នក។

ប្រសិនបើលោកអ្នកមិនអាចបោះឆ្នោតនៅចំថ្ងៃបោះឆ្នោតបានទេ លោកអ្នកប្រហែលជាអាចបោះឆ្នោតនៅតាមមជ្ឈមណ្ឌលបោះឆ្នោមុនពេល ឬដាក់ពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍។ សូមចងចាំថា ប្រសិនបើលោកអ្នកមិនដាក់ពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍ទេ គេនឹងមិនអាចផ្ញើសន្លឹកឆ្នោតទៅលោកអ្នកឡើយ លុះត្រាតែបេក្ខជនឈរឈ្មោះបោះឆ្នោតត្រូវបានសំរេចជាចុងក្រោយបង្អស់។

សូមមើលនៅត្រង់វិបសាយរបស់ AEC ដើម្បីទទួលយកព័ត៌មានបន្ថែមអំពីជំរើសទាំងនេះ។

## របៀបបោះឆ្នោត

សំរាប់ការបោះឆ្នោតសហព័ន្ធ លោកអ្នកនឹងបានទទួលសន្លឹកឆ្នោតពីរសន្លឹក។ សន្លឹកឆ្នោតពណ៌បៃតង គឺសំរាប់សភាតំណាងរាស្ត្រ ហើយសន្លឹកឆ្នោតពណ៌សគឺសំរាប់ព្រឹទ្ធសភា។

នៅពីលើសន្លឹកឆ្នោតពណ៌បៃតង លោកអ្នកត្រូវតែគូសដាក់លេខគ្រប់ទាំងប្រអប់ ទៅតាមលំដាប់នៃការចូលចិត្តរបស់លោកអ្នក។

នៅពីលើសន្លឹកឆ្នោតពណ៌ស លោកអ្នកអាចជ្រើសរើសយកជំរើសមួយ នៃជំរើសពីរដើម្បីបោះឆ្នោត។ លោកអ្នកអាចគូសដាក់លេខ '1' នៅក្នុងប្រអប់ពីលើខ្សែបន្ទាត់ពណ៌ខ្មៅសំរាប់គណៈបក្ស ឬក្រុមនៃជំរើសរបស់លោកអ្នក ឬលោកអ្នកអាចបំពេញនៅក្នុងគ្រប់ទាំងប្រអប់នៅក្រោមខ្សែបន្ទាត់ខ្មៅ ទៅតាមលំដាប់នៃការចូលចិត្តរបស់លោកអ្នក។

លោកអ្នកអាចរៀនដឹងច្រើនថែមទៀតអំពីរបៀបបោះឆ្នោត របៀបដែលគេរាប់សន្លឹកឆ្នោត ហើយនិងរបៀបប្រព័ន្ធបោះឆ្នោតមានដំណើរការ ដោយបើកមើលនៅតាមវិបសាយរបស់ AEC។ (ថែមទាំងមានកន្លែងដែលលោកអ្នកអាចហាត់រៀនបោះឆ្នោតផងដែរ!)។

ប្រសិនបើលោកអ្នកមិនបំពេញសន្លឹកឆ្នោតបានត្រឹមត្រូវទេ នោះគេនឹងមិនអាចរាប់សន្លឹកឆ្នោតរបស់លោកអ្នកឡើយ។

## តើខ្ញុំត្រូវបោះឆ្នោតឲ្យនរណា?

លោកអ្នកបោះឆ្នោតជ្រើសរើសមនុស្សឲ្យធ្វើជាអ្នកតំណាងលោកអ្នក នៅក្នុងរដ្ឋសភាសហព័ន្ធអូស្ត្រាលីនៅក្រុង Canberra (ឃែនបើរ៉ា)។

រដ្ឋសភាគឺជាមជ្ឈមណ្ឌលរបស់រដ្ឋាភិបាលដែលធ្វើការសំរេច ហើយអនុម័តច្បាប់លើរឿងទាំងឡាយដែលប៉ះពាល់ដល់យើងគ្រប់រូប។

នៅក្នុងការបោះឆ្នោតសហព័ន្ធ លោកអ្នកជ្រើសរើសសមាជិកមួយចំនួនឲ្យធ្វើជាតំណាងលោកអ្នកនៅសភាពីរ ដែលមានសភាសហព័ន្ធ – សភាតំណាងរាស្ត្រ និងព្រឹទ្ធសភា។

សំរាប់សភាតំណាងរាស្ត្រ ប្រទេសអូស្ត្រាលីបានចែកជា១៥០តំបន់ ហៅថាមណ្ឌលបោះឆ្នោត។ លោកអ្នកបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភាមួយរូបដើម្បីធ្វើជាតំណាងមណ្ឌលបោះឆ្នោតរបស់លោកអ្នក។

សំរាប់ព្រឹទ្ធសភា រដ្ឋនីមួយៗមានព្រឹទ្ធសភា១២រូប ហើយដែនដីនីមួយៗ (NT និង ACT) មានព្រឹទ្ធសភាពីររូប។ លោកអ្នកបោះឆ្នោតជ្រើសរើសព្រឹទ្ធសភាឲ្យធ្វើជាតំណាងរដ្ឋ ឬដែនដីទាំងមូលរបស់លោកអ្នក។

## កិច្ចបំរើបកប្រែភាសា

អ្នកទូរស័ព្ទដែលគ ឬថ្លង់ ឬមានពិការភាពខាងការស្តាប់ឮ / បញ្ហាក្នុងការនិយាយ អាចទូរស័ព្ទតាមរយៈ National Relay Service (កិច្ចបំរើជាតិផ្នែកបញ្ជូនត)។ អ្នកប្រើប្រាស់កិច្ចបំរើ TTY អាចប្រើទូរស័ព្ទលេខ **133 677** រួចស្នើសុំឲ្យគេទូរស័ព្ទទៅលេខ **13 23 26**។ អ្នកប្រើប្រាស់កិច្ចបំរើ Speak and Listen (ការបញ្ជូនតតាមពាក្យសម្តី-ទៅ-ពាក្យសម្តី) អាចទូរស័ព្ទលេខ **1300 555 727** រួចស្នើសុំឲ្យគេទូរស័ព្ទទៅលេខ **13 23 26**។

អ្នកប្រើការទាក់ទងបញ្ជូនតតាមអ៊ីនធើណឹត អាចតភ្ជាប់ទៅ NRS រួចស្នើសុំឲ្យគេទូរស័ព្ទទៅលេខ **13 23 26**។

ដើម្បីទទួលយកជំនួយនៅក្នុងភាសាដែលលោកអ្នកនិយមចូលចិត្ត សូមទូរស័ព្ទលេខខាងក្រោមនេះ។

ភាសាខ្មែរ **1300 720 134**

Australian Electoral Commission (AEC) ចាត់ចែងការបោះឆ្នោតសហព័ន្ធ និងការបោះឆ្នោតប្រជាមតិ មើលខុសត្រូវបញ្ជីបោះឆ្នោត ហើយផ្តល់ព័ត៌មាន និងកម្មវិធីអប់រំលើការបោះឆ្នោតមួយចំនួន។

Authorised by Gail Urbanski, West Block Offices, Queen Victoria Terrace, Parkes ACT 2600.

AEC 0111_04.09